

# អ្នកទាមទារយុត្តិធម៌៖ កាលប៉ាណា ចាកម៉ា

HerStory Foundation

Let's Read

The Asia Foundation



កាលពីយូរលង់ណាស់មកហើយ មានក្មេងស្រីដ៏អស្ចារ្យម្នាក់ឈ្មោះ កាលប៉ាណា ចាកម៉ា រស់នៅតំបន់កូនភ្នំ ជីតាហ្គុងក្នុងប្រទេសបង់ក្លាដែស។ នាងជាកូនអ្នកស្រុកភ្នំមួយកន្លែងឈ្មោះថា ចាកម៉ា ដែលប្រជាជននៅទីនោះមានភាសាផ្ទាល់ខ្លួន និងមានទំនៀមទម្លាប់ប្លែកគេ ហើយថែមទាំងមានគ្រួសាររាជវង្សទៀតផង!



នៅក្នុងសាលារៀន កាលប៉ាណា បានសង្កេតឃើញថា នាងត្រូវគេរើសអើង ខុសពីមិត្តរួមថ្នាក់ឯទៀតជាជនជាតិបង់ហ្គាលី។ នាងត្រូវគេដាក់ឈ្មោះផ្សេងៗ ឱ្យអង្គុយនៅតុក្រោយគេក្នុងថ្នាក់ និងធ្វើការងារលំបាកៗ។ ទាំងអស់នេះធ្វើឱ្យ កាលប៉ាណា ឆ្ងល់យ៉ាងខ្លាំងថា ហេតុអ្វីបានជាអ្នកខ្លះគេរើសអើងដោយសារតែភាសា ឬគ្រួសាររបស់ពួកគេ? នាងបានគិតអំពីរឿងនេះអស់ជាច្រើនថ្ងៃ ប៉ុន្តែនៅតែមិនអាចរកចម្លើយឃើញ។



ពេលនាងធំឡើង ភាពអយុត្តិធម៌ក៏មានកាន់ច្រើនឡើង។ អ្នកភូមិរបស់នាងត្រូវបានគេរើសអើងដោយមិនឱ្យពួកគេមានការងារ និងដីដូចគេឡើយ ហើយថែមទាំងរើសអើងមិនចាត់ទុកជាភ្ញៀវផងដែរ។ ដោយសារតែបែបនេះ កាលប៉ាណាបានចាប់ផ្តើមបញ្ចេញមតិយ៉ាងម៉ឺងម៉ាត់នៅក្នុងបាតុកម្មប្រឆាំងនឹងការរើសអើងននេះ។ បន្ទាប់ពីក្បួនបាតុកម្មរួច អ្នកស្រុករបស់នាងមានកម្លាំងចិត្តយ៉ាងខ្លាំង។



កាលប៉ាណា ក្លាហានក្នុងការទាមទារសិទ្ធិសេរីភាពស្មើគ្នាលើ ដីធ្លី និងការអប់រំសម្រាប់សហគមន៍។ ថ្ងៃមួយ នាងបានធ្វើការ តវ៉ាយ៉ាងខ្លាំង។ បុរសមួយក្រុមបានតាមចាប់ខ្លួននាង និង បក្សពួករបស់នាង។ ទោះបីជាប្រុសៗបានគេចខ្លួនអស់ ប៉ុន្តែ នាងមិនបានត្រលប់មកវិញនោះទេ។



មួយរយៈក្រោយមក អ្នកស្រុកភ្នំបានធ្វើកិច្ចព្រមព្រៀងសន្តិភាព
មួយដើម្បីការពារសិទ្ធិរបស់ពួកគេ និងប្រាកដថាសហគមន៍
ដែលមានវប្បធម៌ និងភាសាផ្សេងៗគ្នាអាចរស់នៅជាមួយគ្នា
ដោយសុខដុមរមនា និងគ្មានការរើសអើង។
យើងមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះ កាលប៉ាណា ប៉ុន្តែ
យើងដឹងថានាងគឺជាគំរូនៃភាពអង់អាចក្លាហាន និងយុត្តិធម៌
សម្រាប់យើងទាំងអស់គ្នា!

Let's Read
The Asia Foundation

HER STORY FOUNDATION

រឿងបំផុសគំនិតនេះ ជាផ្នែកមួយនៃកម្រង ”ហឺស្តូរី” ដែលបង្កើតឡើងដោយមូលនិធិ ”ហឺស្តូរី” និងសម្រួលទៅជាសៀវភៅនីមួយៗ ក្រោមកិច្ចសហការជាមួយនឹងគំនិតផ្តួចផ្តើមរបស់កម្មវិធីតោះអានរបស់អង្គការមូលនិធិអាស៊ី។

សម្រាប់ព័ត៌មានបន្ថែមអំពី ”ហឺស្តូរី” សូមចូលទៅកាន់ www.herstorybd.org

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*মানবাধিকার কর্মী - কল্পনা চাকমা (The Advocate: Kalpana Chakma)*, Author: HerStory Foundation. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2021. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/
Contributing translators: